# ស្ថានីយធាតុអាកាស ស្ត្រីឆ្នើម និងការគ្រប់គ្រងទឹក

# ការផ្លាស់ប្តូរទម្រង់នៃការជូនដំណឹងជាមុន នៅកម្ពុជា



ការពង្រឹងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធជូនដំណឹងជាមុនដើម្បីគាំទ្រដល់ការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ

របាយការណ៍ឆ្លុះបញ្ចាំងឡើងវិញទី ១ ២០១៥-២០២០

ឯកសារនេះត្រូវបានបោះពុម្ពផ្សាយក្រោមគម្រោង «ពង្រឹងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធជូនដំណឹងជាមុននៅកម្ពុជាដើម្បីគាំទ្រដល់ការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ»។

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា ផ្ទះលេខ ៥៣ វិថីប៉ាស្ទ័រ សង្កាត់បឹងកេងកង ១ ប្រអប់សំបុត្រ ៨៧៧ ក្រុងភ្នំពេញ
ទូរស័ព្ទ ៖ +855 23 216 167/214 371 ទូរសារ ៖ +855 23 216 257/721 042
www.kh.undp.org

**សមាជិកក្រុមបោះពុម្ពផ្សាយ**

Kate Jean Smith អ្នកឯកទេសផ្នែកទំនាក់ទំនង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ( UNDP )
Kelsea Clingeleffer ទីប្រឹក្សាផ្នែកពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍លទ្ធផល ( UNDP ប្រចាំនៅកម្ពុជា )
Muhibuddin Usamah ប្រធានគម្រោង ( UNDP ប្រចាំនៅកម្ពុជា )

ទីកន្លែង និងកាលបរិច្ឆេទបោះពុម្ពផ្សាយ ៖ ក្រុងភ្នំពេញ ខែ ឧសភា ឆ្នាំ ២០២០

គម្របមុខ ៖ ©ប៊ុត ម៉ានុត /UNDP ប្រចាំនៅកម្ពុជា



ប្រជាជនកម្ពុជាប្រមាណ ១ ភាគ ៣ ពឹងផ្អែកលើកសិកម្ម។
©UNDP ប្រចាំនៅកម្ពុជា

# ខ្លឹមសារសង្ខេប

គ្រោះមហន្តរាយដែលបង្កឡើងដោយវិបត្តិអាកាសធាតុ កាន់តែបង្កផលប៉ះពាល់ធ្ងន់ធ្ងរឡើងៗលើជីវិត និងជីវភាពរស់នៅ ហើយត្រូវបានព្យាករថានឹងធ្វើឱ្យផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ថយចុះ ៩,៨% ត្រឹមឆ្នាំ ២០៥០ សូម្បីតែក្នុងសេណារីយ៉ូដែលមានសុទិដ្ឋិនិយមបំផុតក៏ដោយ[១] ។ ជាការឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះប្រទេសកម្ពុជាកំពុងរៀបចំ**ដំណោះស្រាយឌីជីថលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយ សម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។** ដំណោះស្រាយនេះត្រូវបានរៀបចំឡើងផ្អែកតាមទិន្នន័យអនឡាញដែលអាចរកបានភ្លាមៗ និងដែលអាចយកទៅប្រើប្រាស់ ដើម្បីកំណត់ដឹងពីនិន្នាការអវិជ្ជមាននានា និងត្រៀមលក្ខណៈឆ្លើយតបចំពោះព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ។ ក្រោមការដឹកនាំរបស់ក្រសួងធនធានទឹក និងឧតុនិយម និងដោយមានការគាំទ្រពីកម្មវិធីបរិស្ថានសកល និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រព័ន្ធឌីជីថលនេះត្រូវបានបង្កើតឡើង និងពង្រីកវិសាលភាពដាក់ឱ្យប្រើប្រាស់នៅគ្រប់ខេត្តក្រុង ក្នុងប្រទេសកម្ពុជា។

តាមរយៈការសហការយ៉ាងជិតស្និទ្ធជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងសហគមន៍ **ស្ថានីយជលសាស្ត្រ និងធាតុអាកាសស្វ័យប្រវត្តិចំនួន ៥៣ ត្រូវបានដំឡើង** ដើម្បីប្រមូលទិន្នន័យអាកាសធាតុតាមប្រព័ន្ធឌីជីថល ដូចជាទិន្នន័យកម្ពស់ទឹកភ្លៀង កម្ពស់ទឹក និងសីតុណ្ហភាព និងបង្កើនសមត្ថភាពជូនដំណឹងជាមុន។ បច្ចុប្បន្នទិន្នន័យដែលផ្តល់ឱ្យភ្លាមៗពីស្ថានីយស្វ័យប្រវត្តិទាំងនេះ ត្រូវបានប្រមូលផ្តុំដាក់នៅកន្លែងតែមួយ គឺនៅក្នុងប្រព័ន្ធគ្រប់គ្រងទឹករួម ដែលដំណើរការតាមប្រព័ន្ធអនឡាញ។

UNDP បានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីសរុបចំនួន ៥៤ នាក់ មកពីក្រសួងធនធានទឹក និងឧតុនិយម ដូចជា អ្នកជំនាញខាងឧតុនិយម អ្នកជំនាញខាងជលសាស្ត្រ មន្ត្រីបច្ចេកទេស និងមន្ត្រីថ្នាក់ខេត្តអំពីការថែទាំស្ថានីយទាំងនេះ។ បន្ថែមលើការផ្តល់លទ្ធភាពឱ្យមន្ត្រីឧតុនិយម និងជលសាស្ត្រសំខាន់ៗ អាចធ្វើការព្យាករ និងបង្កើតគំរូអាកាសធាតុយ៉ាងសុក្រឹត ដោយប្រើប្រាស់ទិន្នន័យដែលប្រមូលបាន ប្រព័ន្ធនេះបានជួយឱ្យមានការផ្លាស់ប្តូរការព្យាករធាតុអាកាសសម្រាប់អនុរដូវ និងរដូវពី ៣ ថ្ងៃ ទៅ ១០ ថ្ងៃ នៅកម្ពុជា និងអនុញ្ញាតឱ្យសហគមន៍អាចត្រៀមខ្លួន ដើម្បីទប់ទល់នឹងគ្រោះមហន្តរាយនានា ក៏ដូចជា បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ដើម្បីជូនដំណឹងដល់សហគមន៍អំពីគ្រោះមហន្តរាយដែលអាចបង្កផលប៉ះពាល់ដល់ពួកគេ សេវាទូរសព្ទជូនដំណឹងជាមុន **EWS១២៩៤ ត្រូវបានពង្រីកដល់អ្នកចុះឈ្មោះថ្មីចំនួន ២៤.៦២៨ នាក់** ក្នុងខេត្តដែលទទួលបានការ គាំទ្រពី UNDP។ បច្ចុប្បន្ននេះ ប្រព័ន្ធត្រូវបានពង្រីកអនុវត្តប្រកបដោយជោគជ័យនៅទូទាំងប្រទេស ដើម្បីធ្វើឱ្យការត្រៀមបង្ការគ្រោះមហន្តរាយកាន់តែមានភាពល្អប្រសើរ។

យន្តការសម្របសម្រួលថ្នាក់ខេត្តសម្រាប់គ្រប់គ្រងគ្រោះរាំងស្ងួត **ត្រូវបានបង្កើតឡើង តាមរយៈការបង្កើតមជ្ឈមណ្ឌលព័ត៌មានគ្រោះរាំងស្ងួត នៅក្នុងខេត្តចំនួន ៨។** មជ្ឈមណ្ឌលព័ត៌មាននេះគាំទ្រដល់អាជ្ញាធរខេត្ត



១ “Addressing Climate Change Impacts On Economic Growth in Cambodia”. Ministry of Economy &Finance, National Council for Sustainable Development, UNDP, May 2018.

ក្នុងការព្យាករពីគ្រោះរាំងស្ងួត និងសម្របសម្រួលការឆ្លើយតបទាន់ពេលវេលា ក៏ដូចជាការអនុវត្តវិធានការកាត់បន្ថយការបាត់បង់នានា ដែលជាការជួយដល់ប្រជាជនជិត ៦ លាននាក់ដែលរស់នៅក្នុងតំបន់ទាំងនេះ[២] ។

គំនិតផ្តួចផ្តើមទាំងនេះនឹងនៅបន្តគង់វង្ស តាមរយៈការចូលរួមយ៉ាងសកម្មពីអាជ្ញាធរមូលដ្ឋាន និងសហគមន៍ ព្រមទាំងការលើកកម្ពស់តួនាទីរបស់ស្ត្រីនៅក្នុងសកម្មភាពអាកាសធាតុ និងតាមរយៈ**ការដាក់ចេញនូវគោលនយោបាយដែលបង្កភាពអនុគ្រោះសំខាន់ៗ។** ក្នុងចំណោមគោលនយោបាយទាំងនេះ នីតិវិធីរួមសម្រាប់ អនុវត្តប្រព័ន្ធជូនដំណឹងជាមុនអំពីមុខសញ្ញាគ្រោះថ្នាក់ចម្រុះត្រូវបានបង្កើតឡើង ដើម្បីបញ្ចូលគ្រោះមហន្តរាយគ្រប់ប្រភេទទាំងអស់ និងដើម្បីពង្រឹងការរៀបចំគោលនយោបាយ និងការរៀបចំស្ថាប័ននៅថ្នាក់ជាតិថ្នាក់ស្រុក និងថ្នាក់សហគមន៍។ នីតិវិធីទាំងនេះត្រូវបានរៀបចំឡើង ផ្អែកតាម**ក្របខ័ណ្ឌកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ** (**២០១៩-២០៣០**)និងផែនការសកសម្មភាពជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយរយៈពេល ៥ ឆ្នាំ (២០១៩-២០២៣ ដែលទទួលបានការគាំទ្រពីគម្រោង។

ការជូនដំណឹងជាមុនបែបថ្មីនៅកម្ពុជាពឹងអាស្រ័យលើគោលនយោបាយអំណោយផល និងដំណោះស្រាយឌីជីថល ដែលរឹងមាំទាំងនេះ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងធានាបាននូវការអភិវឌ្ឍដែលធន់ទៅនឹងអាកាសធាតុក្នុងឆ្នាំបន្តបន្ទាប់ខាងមុខនេះ។



កសិករជួបជុំគ្នាក្រោមដើមឈើនៅពេលព្យុះជិតមកដល់ ក្នុងពេលចុះផ្លាស់ប្តូរបទពិសោធន៍បណ្តុះបណ្តាលក្នុងខេត្តកំពង់ឆ្នាំង (©Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )។

២ "General Population Census of the Kingdom of Cambodia 2019" National Institute of Statistics, Kingdom of Cambodia, June 2019.



ប្រជាពលរដ្ឋកម្ពុជាជាច្រើនពឹងផ្អែកលើរបរនេសាទដើម្បីទទួលបានអាហារ
និងប្រកបរបរចិញ្ចឹមជីវិត (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)។



នៅកម្ពុជា គ្រោះមហន្តរាយដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុកំពុងជះផលអវិជ្ជមានលើអាយុជីវិត និងរបរចិញ្ចឹមជីវិត និងបំផ្លិចបំផ្លាញសេដ្ឋកិច្ចយ៉ាងដំណំ។

ការខូចខាតដែលបង្កឡើងដោយខ្យល់ព្យុះកេតសាណា នៅឆ្នាំ ២០០៩ បានធ្វើឱ្យខាតបង់ទឹកប្រាក់ **១៣០** លានដុល្លារ។

គ្រោះទឹកជំនន់នៅឆ្នាំ ២០១១ ធ្វើឱ្យប៉ះពាល់ដល់ដីកសិកម្ម **៦៨៣.៤៩៨** ហិចតា ដែលធ្វើឱ្យខាតបង់ទឹកប្រាក់ **៤៥១** លានដុល្លារ និងបង្កការខាតបង់ចំនួន **១៧៤** លានដុល្លារដល់វិស័យផ្សេងៗក្នុងសេដ្ឋកិច្ច។

យោងតាមមូលដ្ឋានទិន្នន័យគ្រោះមហន្តរាយអន្តរជាតិ EM-DAT កម្ពុជាប្រឈមនឹងគ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងអាកាសធាតុចំនួន ១៩ នៅអំឡុងឆ្នាំ ១៩៩០-២០០៩ ដែលធ្វើឱ្យប្រជាជនជាង ១.០០០ នាក់ស្លាប់ និងជាង ១៦ លាននាក់ទៀតរងផលប៉ះពាល់។

កម្ពុជាប្រឈមនឹងបញ្ហាអភិវឌ្ឍន៍ជាច្រើន ដោយសាររដូវប្រាំងអូសបន្លាយ និងរដូវវស្សាកាន់តែខ្លី និងអាក្រក់ជាងមុន និងការកើតមានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតកាន់តែញឹកញាប់។

ការស្តារឡើងវិញពីព្រឹត្តិការណ៍ទាំងនេះ បានធ្វើឱ្យខាតបង់ធនធានសាធារណៈ និងបង្ខំឱ្យមានការផ្លាស់ប្តូរអាទិភាពអភិវឌ្ឍន៍។

ទន្ទឹមនឹងនេះ ការប្រែប្រួលអាកាសធាតុកំពុងបង្កផលប៉ះពាល់លើផលិតកម្មកសិកម្ម ដែលធ្វើឲ្យប៉ះពាល់ដល់ប្រាក់ចំណូលគ្រួសារ និងដាក់សម្ពាធលើសន្តិសុខស្បៀង។

ប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធជូនដំណឹងជាមុនដើរតួនាទីយ៉ាងសំខាន់ក្នុងការប៉ាន់ស្មានគ្រោះមហន្តរាយ និងការចាត់វិធានការ។

ប្រព័ន្ធជូនដំណឹងជាមុន មានតួនាទីពិនិត្យតាមដានទិន្នន័យអាកាសធាតុ និងទិន្នន័យបរិស្ថានទៅតាមភាពជាក់ស្តែង និងកំណត់រកនិន្នាការអវិជ្ជមាន។

ប្រព័ន្ធជូនដំណឹងជាមុនដែលមានប្រសិទ្ធភាពផ្តល់ការឆ្លើយតបទាន់ពេលវេលាទៅនឹងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ និងព្រឹត្តិការណ៍ធាតុអាកាសមិនល្អ។

ព័ត៌មានដូចគ្នានេះក៏មានសារៈសំខាន់សម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ដោយផ្អែកតាមហានិភ័យផងដែរ។



ការកើនឡើងនៃនីវ៉ូទឹកសមុទ្រ អាចបង្កផលប៉ះពាល់ដល់ប្រព័ន្ធឆ្នេរសមុទ្រកម្ពុជាតាមវិធីជាច្រើន( ©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា )។

# ការពង្រឹងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធជូនដំណឹងជាមុនដើម្បីគាំទ្រដល់ការអភិវឌ្ឍដែលធន់នឹងអាកាសធាតុនៅកម្ពុជា

ដោយកត់សម្គាល់ពីបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកព័ត៌មានអាកាសធាតុ និងការបង្កើតប្រព័ន្ធជូនដំណឹងជាមុនដែលមានប្រសិទ្ធភាព ជាចំណុចអាទិភាព។

ក្រោមជំនួយហិរញ្ញវត្ថុពី Global Environment Facility-មូលនិធិសម្រាប់ប្រទេសអភិវឌ្ឍន៍តិចបំផុត និងជំនួយបច្ចេកទេសពី UNDP គម្រោង “ពង្រឹងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធជូនដំណឹងជាមុនដើម្បីគាំទ្រដល់ការអភិវឌ្ឍដែលធន់នឹងអាកាសធាតុនៅកម្ពុជា” (២០១៥-២០២០)បានជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលុបបំបាត់ចំណុចខ្វះខាតក្នុងសមត្ថភាពស្ថាប័ន ការសម្របសម្រួលអន្តរក្រសួង និងហេដ្ឋារចនាសម្ព័ន្ធ។

គម្រោងនេះផ្តោតលើលទ្ធផលបំពេញឱ្យគ្នា ៣ ៖

1 

បង្កើនសមត្ថភាពស្ថាប័នក្នុងការប្រមូល និងព្យាករណ៍ព័ត៌មានធាតុអាកាស ជលសាស្ត្រ អាកាសធាតុ និងបរិស្ថាន

2 

មានព័ត៌មានអាកាសធាតុ និងធាតុអាកាស សម្រាប់ការរៀបចំផែនការថ្នាក់ជាតិ ថ្នាក់វិស័យ និងថ្នាក់ក្រោមជាតិ និងការផ្សព្វផ្សាយឆ្លងដែនក្នុងតំបន់

3 

ពង្រឹងសមត្ថភាពស្ថាប័នក្នុងការដំណើរការ និងជួសជុលថែទាំប្រព័ន្ធជូនដំណឹងជាមុន និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានអាកាសធាតុ ទាំងផ្នែកទន់ និងផ្នែករឹង ដើម្បីពិនិត្យតាមដានធាតុអាកាស។

ក្រោមការដឹកនាំដោយក្រសួងធនធានទឹក និងឧតុនិយម និងវិសាលភាពទូទាំង ២៥ ខេត្តក្រុង គម្រោងបានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

សៀវភៅរូបថតនេះបង្ហាញពីសមិទ្ធផលគម្រោង និងរបៀបដែលគម្រោងគាំទ្រដល់កម្ពុជាក្នុងការសម្រេចបានអនាគតដែលកាន់តែមាននិរន្តរភាព និងធន់នឹងអាកាសធាតុ។



ក្នុងស្ថានភាពនៃការប្រែប្រួលអាកាសធាតុ មុខសញ្ញាគ្រោះថ្នាក់ធម្មជាតិអាចកើតឡើងកាន់តែញឹកញាប់ ហើយប្រជាជនក្រីក្រងាយរងផលប៉ះពាល់ខ្លាំងជាងគេ (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)។



គ្រួសារធ្វើកសិកម្ម ២០% មានស្ត្រីជាមេគ្រួសារ។ ក្នុងនោះ ស្ត្រី ៩ នាក់ក្នុងចំណោម ១០ នាក់ ជាមេគ្រួសារ “ពិតប្រាកដ” ឬ “ជាក់ស្តែង” ដោយគ្មានវត្តមានប្តី ឬសមាជិកគ្រួសារជាបុរសពេញវ័យជាអចិន្ត្រៃយ៍ ( ©UNDP )។

# មាតិកា

**ខ្លឹមសារសង្ខេប** ..... IV
**ប្រវត្តិនៃប្រព័ន្ធជូនដំណឹងជាមុននៅកម្ពុជា** ..... 1
**ទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធពិនិត្យតាមដាន** ..... 4
ស្ថានីយធាតុអាកាស និងស្ថានីយជលសាស្រ្តស្វ័យប្រវត្តិថ្មីៗ ..... 8
វេទិកាអនឡាញសម្រាប់ការព្យាករណ៍ និងការជូនដំណឹងជាមុន ..... 11

**ការកសាងសមត្ថភាពថ្នាក់ជាតិ** ..... 14
ការបង្កើនការព្យាករណ៍ធាតុអាកាសសម្រាប់កសិករ ..... 18
ការដំណើរការ និងការជួសជុលថែទាំស្ថានីយ ត្រួតពិនិត្យនៅថ្ងៃអនាគត ..... 19

**ការគ្រប់គ្រងគ្រោះរាំងស្ងួត** ..... 26
មជ្ឈមណ្ឌលព័ត៌មានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ..... 28
ការបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្ម ដែលធន់នឹងគ្រោះរាំងស្ងួត ..... 28
ចំណុចឱ្យសញ្ញាថានឹងមានគ្រោះរាំងស្ងួត ..... 34

**សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី** ..... 36
ការបង្កើនភាពអង់អាចរបស់ស្ត្រីក្នុងសកម្មភាព អាកាសធាតុ ៖ “ស្ត្រីឆ្នើម” ..... 38
“បញ្ជីតម្រូវការ” កំណត់អាទិភាពរបស់ស្ត្រី ..... 41
ការស្វែងយល់ពីបទពិសោធន៍របស់ស្ត្រីកម្ពុជាតាមរយៈ “សន្ទស្សន៍ភាពធន់របស់ស្ត្រី” ..... 42
**ប្រព័ន្ធជូនដំណឹងជាមុន EWS១២៩៤** ..... 44

**ការប្រើប្រាស់ព័ត៌មានអាកាសធាតុ** ..... 48
សាលា FARM ..... 50
កម្មវិធី SESAME ..... 52

**ការចែករំលែកឆ្លងដែន** ..... 54
សន្និសីទស្តីពីប្រព័ន្ធជូនដំណឹងជាមុនក្នុងតំបន់ទន្លេមេគង្គក្រោម ..... 57

**ការពន្លឿនការតាក់តែងគោលនយោបាយ** ..... 60
នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ប្រព័ន្ធជូនដំណឹងជាមុនពីមុខសញ្ញាគ្រោះថ្នាក់ចម្រុះ ..... 62
យុទ្ធសាស្រ្តជាតិសម្រាប់ការគ្រប់គ្រងទឹកក្រោមដី ..... 63
យុទ្ធសាស្រ្តជាតិសម្រាប់ការគ្រប់គ្រងគ្រោះរាំងស្ងួត ..... 63
សៀវភៅណែនាំស្តីពីការគ្រប់គ្រងគ្រោះរាំងស្ងួត សម្រាប់អ្នកជំនាញ ..... 63
ក្របខណ្ឌជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៩-២០៣០ និងផែនការសកម្មភាព ៥ ឆ្នាំ ..... 65
ការសិក្សាពីការគ្រប់គ្រងទឹកជំនន់ និងប្រព័ន្ធជូនដំណឹងជាមុន ក្នុងអាងស្ទឹងព្រែកត្នោត ..... 66
យុទ្ធសាស្រ្តជាតិសម្រាប់ការជំរុញការចូលរួមរបស់វិស័យឯកជន ក្នុងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធជូនដំណឹងជាមុន ..... 68

**ការធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យគ្រោះមហន្តរាយជាតិរបស់កម្ពុជា (CAMDI)** ..... 70
**លទ្ធផលគម្រោង** ..... 74



ស្ថានីយធាតុអាកាសទីមួយរបស់កម្ពុជា ស្ថិតក្នុងខេត្តកំពង់ចាម
(©Cedric Jancloes/UNDP ប្រចាំនៅកម្ពុជា )

# ប្រវត្តិនៃប្រព័ន្ធជូនដំណឹងជាមុន ក្នុងប្រទេសកម្ពុជា

លោក សេង សុផា ដែលកំពុងអង្គុយនៅមាត់ទន្លេក្បែរស្ថានីយធាតុអាកាសស្វ័យប្រវត្តិថ្មីមួយ បានរំលឹកឡើងវិញពីប្រវត្តិនៃការសាងសង់ស្ថានីយឧតុនិយមដំបូងគេក្នុងប្រទេសកម្ពុជា។ គាត់បានពន្យល់ថា នៅដើមសតវត្សរ៍ទី ២០ មានការសាងសង់ប៉ុស្តិ៍មួយក្នុងក្រុងកំពង់ចាម។ ប៉ុស្តិ៍នេះជាទីតាំងពាណិជ្ជកម្មយុទ្ធសាស្ត្រនៅតាមដងទន្លេមេគង្គសម្រាប់រដ្ឋបាលបារាំង។

អគារនេះនៅមានស្ថានភាពល្អ ប៉ុន្តែនៅពេលខ្មែរក្រហមឡើងកាន់អំណាច អគារនេះរងការខូចខាតបន្តិចបន្តួច។ ក្រោយសង្គ្រាម ប៉ុស្តិ៍នេះបានក្លាយជាស្ថានីយឧតុនិយម។ នោះជាពេលដែលលោក សេង សុផា និងមិត្តភក្តិនៅរៀនម្នាក់របស់គាត់ (លោក អូវ ស៊ីមហេន) បានសហការគ្នាប្រមូលទិន្នន័យស្តីពីកម្រិតទឹកទន្លេក្នុងមូលដ្ឋាន ទឹកភ្លៀង ខ្យល់ និងពន្លឺព្រះអាទិត្យ។ ពួកគាត់ជាបុគ្គលិកដំបូងគេដែលប្រចាំការនៅស្ថានីយទីមួយរបស់កម្ពុជា។ ក្រោយពេលដែលស្ថានីយនេះត្រូវបានកសាងឡើងនៅឆ្នាំ ១៩៨១ កងទ័ពវៀតណាមកំពុងប្រយុទ្ធជាមួយពួកឧទ្ទាមខ្មែរក្រហមនៅជិតៗនោះនៅឡើយ។

សង្គ្រាមបានកន្លងផុតទៅ ហើយស្នាមញញឹមបានត្រឡប់មកជាថ្មី។ ពួកគាត់បានឯកភាពគ្នា នៅពេលនិយាយរំលឹកឡើងវិញពីរបៀបដែលពួកគាត់បានជិះកង់ចុះតាមស្ថានីយមួយចំនួនក្នុងចំណោមស្ថានីយទាំង ១០ នៅទូទាំងខេត្តកំពង់ចាមនៅរៀងរាល់ម៉ោង ៧ ព្រឹក ១១ ថ្ងៃត្រង់ និង ៧ ល្ងាច។ ពួកគាត់ធ្វើកិច្ចការនេះជារៀងរាល់ថ្ងៃ។ វិធីតែមួយគត់ដែលពួកគាត់អាចចូលរួមព្រឹត្តិការណ៍ និងពិធីបុណ្យសំខាន់ៗគឺត្រូវប្តូរវេនគ្នា។

ជារួម ពួកគាត់បានបណ្តាក់គ្នាធ្វើកិច្ចការនេះក្នុងរយៈពេលជិត ៤០ ឆ្នាំ។ លោក សេង នៅចាំពីការលំបាកនៃការប្រើប្រាស់នាឡិកាដែលត្រូវបិទជារៀងរាល់ថ្ងៃ។ ការផ្លាស់ប្តូរហ្វីលផូតូរ៉ុលសម្រាប់ម៉ែត្រពន្លឺ ក៏ត្រូវចំណាយពេលយូរផងដែរ ដែលធ្វើឱ្យពួកគាត់នៅតែនឹកឃើញមិត្តចាស់ៗ។

ក្រោយការបង្រួបបង្រួមជាតិនៅឆ្នាំ ១៩៩៦ ស្ពានថ្មីមួយបានតភ្ជាប់ប្រទេសកម្ពុជាទៅនឹងប្រទេសវៀតណាម។ ពាណិជ្ជកម្មកសិកម្មបានចាប់ផ្តើមរីកដុះដាលជាថ្មី និងមានការដាំដុះស្រូវ ពោតក្រហម និងដំឡូងមីក្នុងមូលដ្ឋាន។





លោក អូវ ស៊ីមហេន ( ឆ្វេង ) និងលោក សេង សុផា ( ស្តាំ ) កំពុងរំលឹកឡើងវិញពីអនុស្សាវរីយ៍ នៃការប្រមូលទិន្នន័យ (©Cedric Jancloes/UNDP ប្រចាំនៅកម្ពុជា )




ការដំឡើងស្ថានីយជលសាស្ត្រ នៅស្ពានតាសាល
ខេត្តកំពង់ស្ពឺ ឆ្នាំ ២០១៨ (©OTTHydromet)

# ទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធពិនិត្យតាមដាន

**ដៃគូ ៖** OTT Hydrometry (ADCON Telemetry; SUTRON)

**ទីតាំង ៖** ទូទាំងប្រទេស

**គោលដៅ ៖** ក្រសួងធនធានទឹក និងឧតុនិយម

**លទ្ធផលសំខាន់ៗ ៖**



**២៤** ស្ថានីយធាតុអាកាសស្វ័យប្រវត្តិ ចំនួន ២៤ ត្រូវបានដំឡើង

**២៩** ស្ថានីយជលសាស្ត្រស្វ័យប្រវត្តិ ចំនួន ២៩ ត្រូវបានដំឡើង



ដោយកត់សម្គាល់ថា ការត្រៀមខ្លួនគឺជាគន្លឹះក្នុងការកាត់បន្ថយការខូចខាត កម្ពុជាបានធ្វើទំនើបកម្មការប្រមូលទិន្នន័យអាកាសធាតុ និងសមត្ថភាពជូនដំណឹងជាមុនពីគ្រោះមហន្តរាយតាមរយៈការដំឡើងស្ថានីយជលសាស្រ្ត និងស្ថានីយធាតុអាកាសស្វ័យប្រវត្តិនៅទូទាំងប្រទេស។

ការព្យាករណ៍ និងការជូនដំណឹងដោយផ្អែកតាមទិន្នន័យទាំងនោះ នឹងជួយឱ្យសហគមន៍ត្រៀមខ្លួនទប់ទល់នឹងស្ថានភាព ឬព្រឹត្តិការណ៍ធាតុអាកាសមិនល្អដែលនឹងកើតឡើង និងសម្រួលដល់ការធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យដែលងាយរងគ្រោះដោយសារធាតុអាកាស ដើម្បីសង្គ្រោះអាយុជីវិតទ្រព្យសម្បត្តិ និងរបរចិញ្ចឹមជីវិត។

ការដំឡើងស្ថានីយធាតុអាកាសស្វ័យប្រវត្តិមួយក្រោមគម្រោងនេះ (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា )





តាមទម្លាប់ ការរាយការណ៍ពីធាតុអាកាស
នៅកម្ពុជាធ្វើឡើងដោយសំណេរ។ ពោលគឺ
មន្ត្រីមន្ទីរធនធានទឹក និងឧតុនិយមកត់ត្រាទិន្នន័យ
ដោយដៃ រួចបញ្ជូនទៅនាយកដ្ឋានឧតុនិយមក្នុង
ក្រុងភ្នំពេញដើម្បីឱ្យអ្នកឧតុនិយមធ្វើការព្យាករណ៍
សម្រាប់រយៈពេល ៣ ថ្ងៃ។

មន្ត្រីមូលដ្ឋាន លោក ឡាក់ ប៉ូលីវណ្ណ ក្នុងខេត្តកោះកុង អោបសៀវភៅកត់ត្រាកម្ពស់ទឹកភ្លៀង នៅជិតកែវវាស់ទឹកភ្លៀង សម្រាប់វាស់កម្ពស់ទឹក (©អ៊ឹម សំរួល/UNDP ប្រចាំនៅកម្ពុជា )។



លោកស្រី អោក ឡេត ដែលជាមន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម ក្នុងខេត្តកោះកុង បង្ហាញពីមធ្យោបាយបែបប្រពៃណីនៃការវាស់កម្ពស់ទឹកភ្លៀងដោយប្រើកែវសម្រាប់វាស់ទឹកភ្លៀងនៅទីធ្លាក្រោយផ្ទះ។ (©អ៊ឹម សំរួល/UNDP ប្រចាំនៅកម្ពុជា)



# ស្ថានីយធាតុអាកាស និងស្ថានីយជលសាស្ត្រស្វ័យប្រវត្តិថ្មីៗ

នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៩ ដែលជាទិវាឧតុនិយមពិភពលោក UNDP បានប្រារព្ធពិធីប្រគល់ជាផ្លូវការនូវស្ថានីយធាតុអាកាស និងស្ថានីយជលសាស្ត្រស្វ័យប្រវត្តិចំនួន ៥៣ ដល់ក្រសួងធនធានទឹក និងឧតុនិយម។

ស្ថានីយទាំងនេះ (ស្ថានីយជលសាស្ត្រ ២៤ សម្រាប់ទឹកលើដី និងស្ថានីយជលសាស្ត្រ ៥ សម្រាប់ទឹកក្រោមដី) ត្រូវបានដំឡើងក្នុងបណ្តាខេត្តភាគអាគ្នេយ៍ ដែលងាយប្រឈមនឹងគ្រោះមហន្តរាយ ដូចជា ខេត្តកោះកុង កំពង់ស្ពឺ តាកែវ កែប ព្រះសីហនុ និងកំពត។

ស្ថានីយធាតុអាកាស ៣ និងស្ថានីយជលសាស្ត្រ ១ ត្រូវបានដំឡើងក្នុងគម្រោងនេះ នៅខេត្តកណ្តាល ហើយស្ថានីយជលសាស្ត្រ ២ ត្រូវបានដំឡើងនៅក្រុងភ្នំពេញ និងស្ថានីយធាតុអាកាសដ៏ទៃទៀត បានដំឡើងក្នុងខេត្តព្រះវិហារ និងកំពង់ចាម។



ស្ថានីយធាតុអាកាសស្វ័យប្រវត្តិមួយ (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)



ស្ថានីយជលសាស្ត្រស្វ័យប្រវត្តិមួយក្នុងចំណោមស្ថានីយជលសាស្ត្រស្វ័យប្រវត្តិផ្សេងទៀត (©OTT HydroMet)



ផ្ទៃគខាងក្នុងនៃស្ថានីយជលសាស្ត្រស្វ័យប្រវត្តិមួយក្នុងចំណោមស្ថានីយជលសាស្ត្រស្វ័យប្រវត្តិផ្សេងទៀត
( ©សយ រដ្ឋា/UNDP ប្រចាំនៅកម្ពុជា )



សែនស័រវាស់កម្រិតទឹកដែលបានដំឡើងលើស្ពានតាតៃ ក្រោមកិច្ចសហការជាមួយអង្គការ People in Need (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)។

## វេទិកាអនឡាញសម្រាប់ការព្យាករណ៍ និងការជូនដំណឹងជាមុន

ដើម្បីឱ្យយល់ វិភាគ និងព្យាករណ៍បានច្បាស់ពីបាតុភូតជលសាស្ត្រ-ឧតុនិយមជាក់ស្តែង គម្រោងបានបង្កើតប្រព័ន្ធចម្រុះសម្រាប់ការគ្រប់គ្រងទឹក ដែលប្រមូលទិន្នន័យពីនាយកដ្ឋានជលសាស្ត្រ និងនាយកដ្ឋានឧតុនិយម។

> “យើងទទួលបានទិន្នន័យជាច្រើនពីផ្កាយរណប រ៉ាដា និងស្ថានីយធាតុអាកាសស្វ័យប្រវត្តិ។ យើងមានតួនាទីប្រមូលទិន្នន័យទាំងអស់ដើម្បីបង្ហាញដល់អ្នកព្យាករណ៍។ បច្ចេកវិទ្យាពិតជាសំខាន់ណាស់។”

**លោក លី ហុន ក្រុមគាំទ្រប្រព័ន្ធ នៃនាយកដ្ឋានឧតុនិយម**





ការសង្កេតមើលទិន្នន័យជាក់ស្តែងនៅមជ្ឈមណ្ឌលប្រតិបត្តិការឧតុនិយមរបស់ក្រសួងធនធានទឹក និងឧតុនិយម ប្រទេសកម្ពុជា។ (© សយ រដ្ឋា/UNDP ប្រចាំនៅកម្ពុជា)



សហគមន៍តំបន់ឆ្នេរក្នុងភូមិបឹងកាចាង ខេត្តកោះកុង (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)



ក្រសួងធនធានទឹក និងឧតុនិយមក្នុង
ក្រុងភ្នំពេញ (©UNDP ប្រចាំនៅកម្ពុជា )

# ការកសាងសមត្ថភាពថ្នាក់ជាតិ

**ដៃគូ ៖** ប្រព័ន្ធជូនដំណឹងពីមុខសញ្ញាគ្រោះថ្នាក់ចម្រុះសម្រាប់តំបន់អាហ្វ្រិក និងអាស៊ី (RIMES), OTT Hydromet, BRL

**ទីតាំង ៖** ទូទាំងប្រទេស

**គោលដៅ ៖** ក្រសួងធនធានទឹក និងឧតុនិយម

**លទ្ធផលសំខាន់ៗ ៖**

**២៩** អ្នកជំនាញឧតុនិយម និងអ្នកជំនាញជលសាស្ត្រ ២៩ នាក់ ត្រូវបានបណ្តុះបណ្តាលពីការបង្កើតគំរូ និងការព្យាករណ៍។

**៥៤** អ្នកជំនាញឧតុនិយម អ្នកជំនាញជលសាស្ត្រ និងអ្នកបច្ចេកទេស ៥៤ នាក់ ត្រូវបានបណ្តុះបណ្តាលពីការដំណើរការ និងការជួលជុលថែទាំស្ថានីយធាតុអាកាស និងស្ថានីយជលសាស្ត្រស្វ័យប្រវត្តិ។



ក្នុងបណ្ដាប្រទេសជាច្រើន
នៅជុំវិញពិភពលោក លទ្ធភាព
ទទួលបានព័ត៌មានព្យាករណ៍ប្រចាំថ្ងៃ
សប្ដាហ៍ និងរដូវកាល គឺជារឿងធម្មតា
ប៉ុន្តែក្នុងបណ្ដាប្រទេស ដូចជា កម្ពុជា
ការព្យាករណ៍ទើបតែចាប់ផ្ដើម
រីកចម្រើនទេ។

អ្នកព្យាករណ៍កំពុងសង្កេតមើលទិន្នន័យជាក់ស្ដែងនៅមជ្ឈមណ្ឌលប្រតិបត្តិការឧតុនិយមក្នុងក្រសួងធនធានទឹក និងឧតុនិយម ក្រុងភ្នំពេញ (©សយ រដ្ឋា/UNDP ប្រចាំនៅកម្ពុជា)





សមាជិកសហគមន៍ និងអាជ្ញាធរមូលដ្ឋានកំពុងចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (©ប៉ិត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)



អ្នកជំនាញឧតុនិយម និង
អ្នកជំនាញជលសាស្ត្រដែលអាច
ព្យាករណ៍ និងបង្កើតគំរូធាតុអាកាស
បានយ៉ាងត្រឹមត្រូវ និងជួសជុល
ថែទាំហេដ្ឋារចនាសម្ព័ន្ធចាំបាច់
ដើរតួនាទីយ៉ាងសំខាន់។

លោកស្រី ទេព ផល្លារ័ត្ន ដែលជាអ្នកជំនាញឧតុនិយមជាន់ខ្ពស់ កំពុងចូលរួម
វគ្គបណ្តុះបណ្តាលនៅខេត្តកំពង់ស្ពឺ (©Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )

## ការបង្កើនការព្យាករណ៍ធាតុអាកាសសម្រាប់កសិករ

កន្លងមក កម្ពុជាគ្រាន់តែអាចព្យាករណ៍ធាតុអាកាសរយៈពេលខ្លីប៉ុណ្ណោះ ប៉ុន្តែក្រោមគម្រោងនេះ អ្នកជំនាញឧតុនិយម និងអ្នកជំនាញជលសាស្ត្រ បានសហការជាមួយដៃគូអន្តរជាតិ ដូចជា ប្រព័ន្ធជូនដំណឹងពីមុខសញ្ញាគ្រោះថ្នាក់ចម្រុះសម្រាប់តំបន់អាហ្វ្រិក និងអាស៊ី (RIMES) ដើម្បីបង្កើនការព្យាករណ៍ពីរយៈពេល ៣ ថ្ងៃ រហូតដល់រយៈពេល ១០ ថ្ងៃ និងផ្លាស់ប្តូរវិធីសាស្ត្រព្យាករណ៍តាមរដូវ និងតាមអនុរដូវ។

ការបណ្តុះបណ្តាលក្រោមគម្រោងនេះរួមមានការបង្កើតគំរូព្យាករណ៍ធាតុអាកាសជាលេខ និងឧបករណ៍ព្យាករណ៍ពីមជ្ឈមណ្ឌលអឺរ៉ុបសម្រាប់ការព្យាករណ៍ធាតុអាកាសរយៈពេលមធ្យម។



កសិករជាស្ត្រីក្នុងខេត្តកំពង់ធំ (©Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )

## ការដំណើរការ និងជួសជុលថែទាំស្ថានីយ ត្រួតពិនិត្យនៅថ្ងៃអនាគត

នៅក្រសួងធនធានទឹក និងឧតុនិយម មូលដ្ឋានទិន្នន័យមួយបង្ហាញពីផែនទីចំណុចពណ៌ជាច្រើន។ ចំណុចពណ៌បៃតង មានន័យថាស្ថានីយធាតុអាកាស ឬស្ថានីយជលសាស្ត្រស្វ័យប្រវត្តិកំពុងដំណើរការល្អ និងផ្តល់ទិន្នន័យជាក់ស្តែង ចំណែកចំណុចពណ៌ក្រហមមានន័យថា ត្រូវផ្តោតការយកចិត្តទុកដាក់លើស្ថានីយណាមួយ។

ក្រោមគម្រោងនេះ អ្នកជំនាញឧតុនិយម អ្នកជំនាញជលសាស្ត្រ និងអ្នកបច្ចេកទេស ៥៤ នាក់ ត្រូវបានបណ្តុះបណ្តាលដោយ OTT Hydrometry ស្តីពីការដំណើរការ និងការជួសជុលថែទាំស្ថានីយធាតុអាកាស និងស្ថានីយជលសាស្ត្រស្វ័យប្រវត្តិ ដើម្បីឱ្យពួកគេអាចពិនិត្យ និងដោះស្រាយបញ្ហាដោយខ្លួនឯងបាន។



ការរៀបចំសែនស័រសម្រាប់ស្ថានីយធាតុអាកាសស្វ័យប្រវត្តិមួយនៅខេត្តព្រះសីហនុ (©ក្រសួងធនធានទឹក និងឧតុនិយម កម្ពុជា)



“យើងបានពង្រីកការព្យាករណ៍របស់យើងពីរយៈពេល ៣ ថ្ងៃ និងរយៈពេល ៧ ថ្ងៃ រហូតដល់រយៈពេល ១០ ថ្ងៃ និងបានធ្វើការព្យាករណ៍អនុវដ្ដផងដែរ។ យើងចង់ផ្ដល់ព័ត៌មានជាមុន។ កន្លងមក ពេលខ្លះ ការផ្ដល់ព័ត៌មានគឺយឺតយ៉ាវខ្លាំងណាស់ ប៉ុន្តែបច្ចុប្បន្ន ប្រជាជននឹងមានពេលត្រៀមខ្លួន និងជម្លៀសចេញ ប្រសិនបើចាំបាច់។”

**លោក អ៊ុំ រីណា ប្រធាននាយកដ្ឋានឧតុនិយម**



លោក អ៊ុំ រីណា ប្រធាននាយកដ្ឋានឧតុនិយមនៃក្រសួងធនធានទឹក និងឧតុនិយម (©ប៊ិត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)។

## វេទិកាខ្យល់មូសុង

វេទិកាខ្យល់មូសុង ផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធជួបជុំគ្នា និងពិនិត្យឡើងវិញលើរដូវខ្យល់មូសុងដែលបានព្យាករណ៍កន្លងមក និងពិភាក្សាពីប្រធានបទដូចជា បទពិសោធន៍ក្នុងវិស័យកសិកម្ម។ ធ្វើដូច្នេះទើបគេអាចកំណត់រក និងដោះស្រាយហានិភ័យបាន។

ក្រោមគម្រោងនេះ UNDP បានរៀបចំវេទិកាជាតិស្តីពីខ្យល់មូសុងនៅកម្ពុជាលើកទី ៧ និងទី ៨ នៅឆ្នាំ ២០១៩ ពោលគឺរយៈពេល ៣ ឆ្នាំក្រោយពេលដែលវេទិកានេះត្រូវបានប្រារព្ធធ្វើឡើងចុងក្រោយក្នុងប្រទេសនេះ។



ឯកឧត្តម ម៉ៅ ហាក់ អគ្គលេខាធិការរងនៃអាជ្ញាធរទន្លេសាប ក្រសួងធនធានទឹក និងឧតុនិយម ក្នុងវេទិកាខ្យល់មូសុងលើកទី ៧ ក្នុងក្រុងភ្នំពេញ ខែ មិថុនា ឆ្នាំ ២០១៩
(©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)









វេទិកាខ្យល់មូសុងលើកទី ៧ ក្នុងក្រុងភ្នំពេញ ខែ មិថុនា ឆ្នាំ ២០១៩ (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)



“ការព្យាករណ៍ធាតុអាកាសយ៉ាងសុក្រឹត្យ និងអាចទុកចិត្ត មានសារៈសំខាន់ណាស់សម្រាប់ប្រទេសទាំងអស់ ជាពិសេសក្នុងស្ថានភាពនៃការប្រែប្រួលអាកាសធាតុ។ ការព្យាករណ៍ផ្តល់ព័ត៌មានស្តីពីអាកាសធាតុក្នុងរយៈពេលប៉ុន្មានខែខាងមុខ ពោលគឺព័ត៌មានដែលជួយឱ្យយើងអាចធ្វើផែនការ ជាពិសេសផែនការវិស័យដែលមានផលិតភាព ដូចជា កសិកម្ម ឬនេសាទ។”

**លោកស្រី ពៅ ផល្លា**

អនុប្រធាននាយកដ្ឋានឧតុនិយម

©សយ រដ្ឋា/UNDP ប្រចាំនៅកម្ពុជា



ទេសភាពពីស្ពានតាតៃ ខេត្តកោះកុង
( ©ប៉ិត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា )



អ្នកចូលរួមម្នាក់កំពុងកត់ត្រាក្នុងវគ្គបណ្តុះបណ្តាលគម្រោង
( © UNDP ប្រចាំនៅកម្ពុជា )



ខេត្តស្ទឹងត្រែង ខែ សីហា ឆ្នាំ ២០១០
(© Arantxa Cedillo/UNDP ប្រចាំនៅកម្ពុជា )

# ការគ្រប់គ្រងគ្រោះរាំងស្ងួត

**ដៃគូ ៖** DanChurchAid Cambodia

**ទីតាំង ៖** ខេត្តកំពង់ស្ពឺ កំពត តាកែវ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ សៀមរាប

**គោលដៅ ៖** ប្រធាន និងសមាជិកសហករណ៍កសិកម្ម និងសមាជិកគណៈកម្មាធិការខេត្តគ្រប់គ្រងគ្រោះមហន្តរាយ

**លទ្ធផលសំខាន់ៗ ៖**



ប្រជាជន **៣.៣០៨** នាក់ ត្រូវបានបណ្តុះបណ្តាលពីការគ្រប់គ្រងគ្រោះរាំងស្ងួត។

កសិករ និងសមាជិកគណៈកម្មាធិការខេត្តគ្រប់គ្រងគ្រោះមហន្តរាយចំនួន **២.៣៨៩** នាក់ ត្រូវបានបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មដែលធន់នឹងគ្រោះរាំងស្ងួត។

ស្ត្រី **១.៤២៥** នាក់ ត្រូវបានបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មដែលធន់នឹងគ្រោះរាំងស្ងួត។



នៅអំឡុងឆ្នាំ ១៩៨៧-២០២០ កម្ពុជាប្រឈមនឹងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ ៦ លើក។ យោងតាមមូលដ្ឋានទិន្នន័យគ្រោះមហន្តរាយអន្តរជាតិ EM-DAT គ្រោះមហន្តរាយទាំងនេះបានបង្កផលប៉ះពាល់កាន់តែខ្លាំងឡើងលើប្រជាពលរដ្ឋកម្ពុជាចំនួន ៩,០៥ លាននាក់។

ស្រុកចិត្របុរី ខេត្តក្រចេះ ឆ្នាំ ២០១០ (©Arantxa Cedillo/UNDP ប្រចាំនៅកម្ពុជា )



ភូមិធ្លកថ្មី ខេត្តស្វាយរៀង ខែ កុម្ភៈ ឆ្នាំ ២០១០ (© Arantxa Cedillo/UNDP ប្រចាំនៅកម្ពុជា )

## មជ្ឈមណ្ឌលព័ត៌មានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

សមត្ថភាពព្យាករណ៍គ្រោះរាំងស្ងួតមានសារៈសំខាន់ណាស់ក្នុងការការពារសុវត្ថិភាពរបរចិញ្ចឹមជីវិត និងកាត់បន្ថយការខាតបង់ និងការខូចខាត។

ក្រោមគម្រោងនេះ មជ្ឈមណ្ឌលព័ត៌មានស្តីពីការគ្រប់គ្រងគ្រោះរាំងស្ងួតចំនួន ៨ ត្រូវបានបង្កើតឡើងក្នុងខេត្តកំពត តាកែវ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ សៀមរាប និងកំពង់ចាម។

តាមរយៈការកៀរគរមន្ត្រីមកពីមន្ទីរផ្សេងៗ ដូចជាមន្ទីរធនធានទឹក និងឧតុនិយម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការខេត្តគ្រប់គ្រងគ្រោះមហន្តរាយ មជ្ឈមណ្ឌលព័ត៌មានទាំងនេះបានបង្ហាញពីការអនុវត្តល្អបំផុតសម្រាប់ការសម្របសម្រួលគ្រោះរាំងស្ងួត និងការឆ្លើយតបជាមុន និងការកាត់បន្ថយផលប៉ះពាល់នៅថ្នាក់ខេត្ត។

## ការបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មដែលធន់នឹងគ្រោះរាំងស្ងួត

ក្រោមការអនុវត្តគំរូនៃការបណ្តុះបណ្តាលគ្រូបង្គោល គម្រោងបានបំពាក់បំប៉នកសិករ និងសមាជិកគណៈកម្មាធិការខេត្តគ្រប់គ្រងគ្រោះមហន្តរាយចំនួន ២.៣៨៩ នាក់ នូវចំណេះដឹងស្តីពីវិធីសាស្ត្រដែលមាននិរន្តរភាពសម្រាប់ការបន្សាំនឹងស្ថានភាពគ្រោះរាំងស្ងួត ដូចជាបច្ចេកទេសសម្រាប់ស្ងួនបន្លែគ្រួសារ ការចិញ្ចឹមមាន់ និងបច្ចេកទេសសន្សំសំចៃទឹក ដូចជា ធារាសាស្ត្របន្តក់ទឹក។

ម៉ូឌុលទាំងនេះត្រូវបានបង្ហាញឡើងក្នុងបរិបទនៃការរៀនសូត្រពីគ្រោះរាំងស្ងួត និងប្រព័ន្ធធាតុអាកាស ដែលអាចឱ្យកសិករព្យាករណ៍បានល្អ និងរៀបចំផែនការសម្រាប់រដូវកាលខាងមុខ។

ដំណើរទស្សនៈកិច្ចផ្លាស់ប្តូរបទពិសោធន៍រវាងសហករណ៍កសិកម្មដែលទទួលបានជោគជ័យ បានសម្រួលដល់ការចែករំលែកបទពិសោធន៍រវាងភូមិនានា។



ការបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មដែលធន់នឹងគ្រោះរាំងស្ងួត ខេត្តបាត់ដំបង ខែ សីហា ឆ្នាំ ២០១៩ (©Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )



ការអនុវត្តការបណ្ដុះសំណាបក្នុងវគ្គបណ្ដុះបណ្ដាលពីបច្ចេកទេសកសិកម្មដែលធន់នឹងគ្រោះរាំងស្ងួត ខេត្តបាត់ដំបង ខែ សីហា ឆ្នាំ ២០១៩ (©Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )



សមាជិកសហករណ៍កសិកម្មកំពុងចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្ម
ដែលធន់នឹងគ្រោះរាំងស្ងួត ខេត្តកំពង់ធំ ខែ កុម្ភៈ ឆ្នាំ ២០២០ (©Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )



“ក្នុងវគ្គបណ្តុះបណ្តាលនេះ យើងអាចត្រៀមខ្លួនបានកាន់តែល្អ។ បច្ចុប្បន្ន យើងមានការយល់ដឹងច្រើនពីគំរូធាតុអាកាស។ ដូច្នេះ យើងអាចកែសម្រួលបច្ចេកទេសបែបប្រពៃណីរបស់យើង។ យើងដឹងពីទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងទឹកជំនន់។ យើងនៅតែមានប្រព័ន្ធជូនដំណឹងបែបប្រពៃណី ប៉ុន្តែការបណ្តុះបណ្តាលសម្រាប់ថ្នាក់គ្រប់គ្រងរបស់យើង បានបង្កើនចំណេះដឹងរបស់យើង។”

**លោក សែម ប៊ុនលី**
ប្រធានសហករណ៍កសិកម្មស្ទឹងស្លាគូ



ប្រធានសហករណ៍កសិកម្មស្ទឹងស្លាគូ លោក សែម ប៊ុនលី (©UNDP ប្រចាំនៅកម្ពុជា )




(© Arantxa Cedillo/UNDP ប្រចាំនៅកម្ពុជា )



## ចំណុចឱ្យសញ្ញាថានឹងមានគ្រោះរាំងស្ងួត

ក្នុងគម្រោងនេះ DanChurchAid និង UNDP បានសហការគ្នាក្រោមការពិគ្រោះយោបល់ជាមួយមន្ទីរធនធានទឹក និងឧតុនិយមដើម្បីបង្កើតបញ្ជី “ចំណុចឱ្យសញ្ញា” ឬកម្រិតចាប់ផ្តើម សម្រាប់ការប្រកាសពីគ្រោះរាំងស្ងួតក្នុងមូលដ្ឋាន (ឧ. ចំណុចឱ្យសញ្ញាសម្រាប់ការប្រកាសពីគ្រោះរាំងស្ងួតជលសាស្រ្ត អាចជាអាងស្តុកទឹកដែលសល់ទឹកតិចជាង ២0%)។

ចំណុចឱ្យសញ្ញា ត្រូវបានបង្កើតឡើងសម្រាប់ខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពត កំពង់ធំ ពោធិ៍សាត់ សៀមរាប និងតាកែវ។



កសិករចូលរួមក្នុងវគ្គបណ្តុះបណ្តាលពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (© /UNDP ប្រចាំនៅកម្ពុជា)



ការស្រាវជ្រាវបង្ហាញថា
ស្ត្រីទទួលរងផលប៉ះពាល់ខ្លាំងដោយ
សារការប្រែប្រួលអាកាសធាតុ ជាហេតុ
ធ្វើឱ្យស្ត្រីប្រឈមនឹងវិសមភាព
កាន់តែខ្លាំង។

នៅកម្ពុជា កម្លាំងពលកម្មជាស្ត្រីប្រមាណ ៣០%
ប្រឡូកក្នុងវិស័យកសិកម្ម ( © /UNDP ប្រចាំនៅកម្ពុជា )

# សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី

**ដៃគូ ៖** អង្គការ ActionAid Cambodia

**ទីតាំង ៖** ខេត្តកំពត កោះកុង ពោធិ៍សាត់

**គោលដៅ ៖** ស្ត្រី និងអាជ្ញាធរមូលដ្ឋាន

**លទ្ធផលសំខាន់ៗ ៖**



**២៣** ស្ត្រីឆ្នើម ២៣ នាក់ ត្រូវបានបណ្តុះបណ្តាល។



“ចាំបាច់ត្រូវទទួលស្គាល់តួនាទីដ៏សំខាន់របស់ស្ត្រីក្នុងសហគមន៍ ព្រោះស្ត្រីចូលរួមយ៉ាងសកម្ម និងប្រកបដោយអត្ថន័យក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការអនុវត្ត និងការផ្តល់យោបល់ត្រឡប់នៅគ្រប់កម្រិត។”

**បណ្ឌិត ប៉ែន រ៉ានី**

ជំនួយការតំណាងប្រជាពលរដ្ឋ និងជាប្រធានកម្មវិធី ( UNDP ប្រចាំនៅកម្ពុជា )



ចំណុចស្នូលនៃរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព គឺការប្តេជ្ញាចិត្តធានា “ការផ្តោតការយកចិត្តទុកដាក់លើមនុស្សគ្រប់រូប” (©Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )



## ការបង្កើនភាពអង់អាចរបស់ស្ត្រីក្នុងសកម្មភាពអាកាសធាតុ ៖ ស្ត្រីឆ្នើម

ក្រោមគម្រោងនេះ អង្គការ ActionAid Cambodia និង UNDP បានសហការគ្នាបណ្តុះបណ្តាលស្ត្រីឆ្នើម ២៣ នាក់ ស្តីពីសមភាពយេនឌ័រ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

នៅពេលទទួលបានការបណ្តុះបណ្តាលជាមួយអាជ្ញាធរមូលដ្ឋាន ស្ត្រីបានក្លាយជាជនបង្គោលនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់សហគមន៍របស់ពួកគាត់ និងរៀបចំផែនការសកម្មភាពសម្រាប់ការជូនដំណឹងជាមុន ដូចជា ការតស៊ូមតិដែលធ្វើឱ្យមានការជីកប្រឡាយមួយខ្សែដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះរាំងស្ងួត ការបណ្តុះបណ្តាលពីសមភាពយេនឌ័រ និងការគ្រប់គ្រងសំណល់ និងការផ្សព្វផ្សាយព័ត៌មានគ្រោះមហន្តរាយ។

ក្រុមស្ត្រីខាងលើបានចូលរួមក្នុងសកម្មភាពផ្សេងទៀតដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ដោយសារគ្រោះមហន្តរាយ ដូចជា យុទ្ធនាការដាំដើមកោងកាងក្នុងខេត្តកំពត និងការស្រាវជ្រាវ និងដំឡើងម៉ាស៊ីនបូមទឹកដើរដោយពន្លឺព្រះអាទិត្យ។



ព្រឹត្តិការណ៍ដាំដើមកោងកាងក្នុងសហគមន៍ក្រោមយុទ្ធនាការ “កោងកាង ១00.000 ដើម” របស់អង្គការ ActionAid ដែលគាំទ្រដោយ UNDP ខែ មីនា ឆ្នាំ ២០២០ (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)

“សង្គមកំណត់ថា ស្ត្រីគឺជាជនរងគ្រោះ។ ពេលខ្លះ សង្គមយល់ថា ស្ត្រីមិនអាចធ្វើកិច្ចការធំបានឡើយ ប៉ុន្តែយើងចង់ធ្វើជាអ្នកដឹកនាំ!”

**លោកស្រី នួន សុធី**



លោកស្រី នួន សុធី ( ខាងស្តាំ ) ក្នុងការបណ្តុះបណ្តាលស្ត្រីឆ្នើម ក្រុងភ្នំពេញ ខែ កញ្ញា ឆ្នាំ ២០១៩ (© Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )



“កាលពីឆ្នាំមុន សហគមន៍របស់ខ្ញុំប្រឈមនឹងបញ្ហាក្នុងការធ្វើស្រែដោយសារគ្រោះរាំងស្ងួត។ ដីជាច្រើនហិចតាត្រូវបានបំផ្លិចបំផ្លាញ។ ស្ត្រីបានជួបជុំគ្នាដើម្បីតស៊ូមតិឱ្យអាជ្ញាធរមូលដ្ឋានជីកប្រឡាយទឹកតូចមួយ។ ឥឡូវយើងលែងមានបញ្ហានេះទៀតហើយព្រោះអាជ្ញាធរបានជីកប្រឡាយនោះមែន! នេះជាសកម្មភាពមួយក្នុងផែនការសកម្មភាពរបស់ខ្ញុំ។”

**លោកស្រី នៅ សំផន**

លោកស្រី នៅ សំផន ក្នុងការបណ្តុះបណ្តាលស្ត្រីផ្តើម
(© Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )

## “ បញ្ជីតម្រូវការ” កំណត់អាទិភាពរបស់ស្ត្រី

ផ្អែកលើទស្សនៈរបស់ស្ត្រី ៣៥០ នាក់មកពីភូមិចំនួន ៣៨ និងអាជ្ញាធរមូលដ្ឋាន និងស្ត្រីឆ្នើម បញ្ជីតម្រូវការរបស់ស្ត្រី បានបង្ហាញពីតម្រូវការ និងអាទិភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅកម្រិតមូលដ្ឋាន។ បញ្ជីតម្រូវការនេះផ្តោតលើការផ្តល់សំឡេងឱ្យស្ត្រីចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួន និងជះឥទ្ធិពលលើអនាគតរបស់ខ្លួន។

ផ្អែកតាមប្រយោគផ្តើមក្នុងបញ្ជីតម្រូវការនេះ “ស្ត្រីមិនសូវទទួលបានឱកាសលើកឡើងពីបញ្ហារបស់ខ្លួនឡើយ។ ក្នុងការប្រមូលទិន្នន័យនេះ ស្ត្រីមានភាពក្លាហានក្នុងការកំណត់រក និងលើកឡើងពីតម្រូវការរបស់ខ្លួន។ ស្ត្រីសង្ឃឹមថានឹងទទួលបានការឆ្លើយតបទាន់ពេលវេលា និងប្រកបដោយការទទួលខុសត្រូវ និងការលើកទឹកចិត្តបន្ថែមទៀតដើម្បីឱ្យស្ត្រីបង្កើនការចូលរួមរបស់ខ្លួនក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។”

ឧទាហរណ៍អាទិភាព រួមមាន ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ និងលទ្ធភាពទទួលបានទឹកស្អាត លទ្ធភាពទទួលបានតំបន់សុវត្ថិភាពដោយមានអាហារគ្រប់គ្រាន់ ថ្នាំសង្កូវ និងធនធានផ្សេងទៀត ការឆ្លើយតបទាន់ពេលវេលា និងគ្រប់គ្រាន់ក្នុងគ្រាអាសន្ន លទ្ធភាពទទួលបានការអប់រំ និងសកម្មភាពកសាងការយល់ដឹង និងការគាំទ្រដល់ការតស៊ូមតិរបស់ស្ត្រី។



សិក្ខាសាលាស្តីពីយេនឌ័រ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ខែ សីហា ឆ្នាំ ២០១៩ (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)



មិត្ត សុមន្ទា មកពីអង្គការ ActionAid Cambodia ក្នុងវគ្គបណ្តុះបណ្តាលស្តីពីសមភាពយេនឌ័រ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ខែ សីហា ឆ្នាំ២០១៩ (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)

## ការស្វែងយល់ពីបទពិសោធន៍របស់ស្ត្រីកម្ពុជាតាមរយៈ "សន្ទស្សន៍ភាពធន់របស់ស្ត្រី"

សន្ទស្សន៍ភាពធន់របស់ស្ត្រី ដែលត្រូវបានបង្កើតឡើងដោយអង្គការ ActionAid ប៉ាន់ប្រមាណភាពធន់របស់ស្ត្រី ធៀបនឹងក្រុមផ្សេងទៀតក្នុងសហគមន៍។ ផ្អែកតាមការពិនិត្យឯកសារពាក់ព័ន្ធ ទិន្នន័យត្រូវបានប្រមូលតាមរយៈការអង្កេតគ្រួសារ កិច្ចពិភាក្សាក្រុមគោលដៅ ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ និងបទសម្ភាសន៍ស៊ីជម្រៅ ដោយផ្តោតសំខាន់លើការច្បាមយកបទពិសោធន៍របស់ក្រុមដែលមិនទទួលបានការយកចិត្តទុកដាក់។

ខណៈដែលការអង្កេតរកឃើញថា ជារួម ប្រជាជនកម្ពុជាមិនសូវមានភាពធន់ មានការគូសបញ្ជាក់ពីគម្លាតយ៉ាងច្រើនរវាងបុរស និងស្ត្រី ដូចជា ប្រាក់ចំណូលប្រចាំថ្ងៃ លទ្ធភាពទទួលបានការអប់រំ សមត្ថភាពអាន និងសរសេរ ឥទ្ធិពលក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការយល់ដឹងពីផែនការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ឃុំ/សង្កាត់។

លទ្ធផលទាំងនេះបានផ្តល់ឧបករណ៍សម្រាប់ការតាក់តែងគោលនយោបាយ ការតស៊ូមតិ ការរៀបចំកម្មវិធីត្រៀមខ្លួនទប់ទល់គ្រោះមហន្តរាយ និងការយល់ដឹងកាន់តែច្បាស់ស្តីពីសហគមន៍ដែលមានសមធម៌។



ស្ត្រីកំពុងអានឯកសារបណ្តុះបណ្តាល ខេត្តកំពង់ធំ
(©Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា)




EWS១២៩៤ គឺជាសេវាទូរស័ព្ទឥតគិតថ្លៃដែលជូនដំណឹងជាមុន ដល់ប្រជាជនពីមុខ
សញ្ញាគ្រោះថ្នាក់ធម្មជាតិដែលនឹងកើតឡើង ( © /UNDP ប្រចាំនៅកម្ពុជា )

# ប្រព័ន្ធជូនដំណឹងជាមុន EWS១២៩៤

**ដៃគូ ៖** អង្គការ People in Need

**ទីតាំង ៖** ខេត្តព្រះសីហនុ កោះកុង កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង តាកែវ កណ្តាល ក្រុងភ្នំពេញ

**គោលដៅ ៖** សហគមន៍មូលដ្ឋាន

**លទ្ធផលសំខាន់ៗ ៖**



ប្រជាពលរដ្ឋកម្ពុជាចំនួន **២៤.៦២៨** នាក់ បានទិញសេវាទូរស័ព្ទជូនដំណឹងជាមុន (EWS១២៩៤ ) ក្នុងបណ្តាខេត្តដែលគាំទ្រដោយ UNDP ក្នុងឆ្នាំ២០១៩ រួមមានខេត្តព្រះសីហនុ កោះកុង កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង តាកែវ កណ្តាល ទីក្រុងភ្នំពេញ កែប និងប៉ៃលិន។

មានការហៅទូរស័ព្ទ **៤៦.៨៥១** ដង ក្នុងបណ្តាខេត្តដែលគាំទ្រដោយ UNDP។



“ប្រជាពលរដ្ឋក្នុងឃុំរបស់ខ្ញុំបានមកប្រាប់ខ្ញុំថា សេវានេះល្អ ព្រោះពួកគាត់ទទួលបានការជូនដំណឹងពីគណៈកម្មាធិការខេត្ត មុនពេលទឹកជំនន់មកដល់! សេវានេះរំលឹកពួកគាត់ពីគ្រោះមហន្តរាយដែលជិតឈានមកដល់ និងជួយឱ្យពួកគាត់ត្រៀមខ្លួនជាមុន។”

**លោកស្រី ទ្រី ទាង មេឃុំបឹងព្រួល**



ការបណ្តុះបណ្តាលសហគមន៍ពីសេវា EWS១២៩៤ ក្នុងខេត្តកំពង់ចាម ខែ សីហា ឆ្នាំ ២០១៩ (© Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )



សមាជិកសហគមន៍កំពុងតែភ្ជាប់សេវា EWS១២៩៤ (© Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )

សេវា EWS១២៩៤ ដែលត្រូវបានដាក់ឈ្មោះតាមលេខកូដចល័តខ្លី ១២៩៤ដែលគាំទ្រដោយរដ្ឋាភិបាលជាសេវាទូរស័ព្ទឥតគិតថ្លៃដែលផ្តល់ការជូនដំណឹងជាមុន និងត្រូវបានបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាល People in Need។

ក្រៅពីការគាំទ្រដល់ការពង្រីកសេវា EWS១២៩៤ ក្នុងខេត្តចំនួន ១១ UNDPបានសហការជាមួយអង្គការ People in Need ដើម្បីសង់ជម្រក និងបង្គន់ដែលផ្តល់ភាពងាយស្រួលដល់ជនពិការ។

គិតត្រឹមពាក់កណ្តាលឆ្នាំ ២០២០ ប្រព័ន្ធនេះត្រូវបានអនុវត្តទូទាំងប្រទេស និងដាក់ឱ្យដំណើរការនៅគ្រប់ខេត្ត។



ហេដ្ឋារចនាសម្ព័ន្ធទីតាំងសុវត្ថិភាពដែលត្រូវបានសាងសង់ក្រោមគម្រោងនេះ ក្នុងខេត្តកំពង់ចាម។ នៅពេលសមាជិកសហគមន៍ទទួលបានការជូនដំណឹងពីគ្រោះមហន្តរាយ ពួកគាត់នឹងអាចប្រមូលធនធាន និងសត្វពាហនៈ ដើម្បីជម្លៀសទៅទីតាំងសុវត្ថិភាពដែលជិតបំផុត។ (©Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )




អ្នកព្យាករណ៍កំពុងសង្កេតមើលទិន្នន័យជាក់ស្តែងនៅមជ្ឈមណ្ឌលប្រតិបត្តិការឧតុនិយមរបស់កម្ពុជា ក្នុងនាយកដ្ឋានឧតុនិយមនៃក្រសួងធនធានទឹក និងឧតុនិយម ក្រុងភ្នំពេញ។ (©សយ រដ្ឋា/UNDP ប្រចាំនៅកម្ពុជា)

# ការប្រើប្រាស់ព័ត៌មានអាកាសធាតុ

ដៃគូ ៖ ប្រព័ន្ធជូនដំណឹងពីមុខសញ្ញាគ្រោះថ្នាក់ចម្រុះសម្រាប់តំបន់អាហ្វ្រិក និងអាស៊ី (RIMES)

អ្នកប្រើប្រាស់ចុងក្រោយ ៖ កសិករ

លទ្ធផលសំខាន់ៗ ៖

**១** ប្រព័ន្ធជំនាញឯកទេស សម្រាប់កម្មវិធីជូនដំណឹងជាមុនពីក្សេត្រឧតុនិយម ( **SESAME** ) ត្រូវបានបង្កើតឡើង។

**១** កម្មវិធីសិក្សាថ្នាក់ជាតិ សម្រាប់សាលា **FARM** ( ការប្រើប្រាស់ការព្យាករណ៍សម្រាប់ការគ្រប់គ្រងហានិភ័យ ) ត្រូវបានរៀបចំឡើង។

**១** តំបន់អាកាសធាតុ ត្រូវបានបង្កើតឡើង។

**១២** បុគ្គលិក ១២ នាក់ នៃនាយដ្ឋានឧតុនិយមត្រូវបានបណ្តុះបណ្តាលដើម្បីផ្តល់ការព្យាករណ៍រយៈពេលវែង។

ការមានសមត្ថភាពប្រើប្រាស់ទិន្នន័យឧតុនិយម និងជលសាស្ត្រ ដើម្បីដោះស្រាយតម្រូវការរបស់ប្រទេសមួយ ជាផ្នែកដ៏សំខាន់មួយនៃការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។



ការបណ្ដុះបណ្ដាលក្នុងសាលា FARM ខេត្តកំពង់ស្ពឺ ខែ កញ្ញា ឆ្នាំ ២០១៩ (©Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )



## សាលា FARM

ការព្យាករណ៍បង្ហាញពីព្រឹត្តិការណ៍ធាតុអាកាសមិនល្អ ដូចជា ខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួត នឹងកើតឡើងញឹកញាប់ និងធ្ងន់ធ្ងរជាងមុននៅទូទាំងប្រទេសកម្ពុជា។

ក្រោមគម្រោងនេះ កម្មវិធីបណ្តុះបណ្តាលស្តង់ដារមួយសម្រាប់ការប្រើប្រាស់ព័ត៌មានអាកាសធាតុក្នុងការធ្វើកសិកម្ម ហៅថា សាលា “FARM”( ការប្រើប្រាស់ការព្យាករណ៍សម្រាប់ការគ្រប់គ្រងហានិភ័យក្នុងវិស័យកសិកម្ម ) ត្រូវបានបង្កើតឡើង ជាមួយ RIMES សម្រាប់ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យកទៅប្រើប្រាស់។

ក្រៅពីការបង្រៀនពីផ្នែកនានានៃការពិនិត្យតាមដានអាកាសធាតុ ការប៉ាន់ស្មាន និងការប្រើប្រាស់ការព្យាករណ៍ កម្មវិធីសិក្សានេះរួមបញ្ចូលការពិភាក្សាជាប្រចាំរវាងកសិករ បុគ្គលិកផ្សព្វផ្សាយ និងអាជ្ញាធរឧតុនិយម។



ការបណ្តុះបណ្តាលក្នុងសាលា FARM
(© Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )



ក្រៅពីការបណ្តុះបណ្តាលពីការបង្កើតគំរូឧតុនិយម  RIMES បានសហការជាមួយ UNDP ដើម្បីបង្កើតកម្មវិធី និងកម្មវិធីសិក្សាមួយដែលគាំទ្រដល់ការប្រើប្រាស់ព័ត៌មានអាកាសធាតុក្នុងបរិបទកម្ពុជា។

ការបណ្តុះបណ្តាលក្នុងសាលា FARM ខេត្តកំពង់ស្ពឺ ខែ កញ្ញា ឆ្នាំ ២០១៩
( © Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )



## កម្មវិធី SESAME

ក្រោមគម្រោងនេះ RIMES បានកែសម្រួលប្រព័ន្ធជំនាញឯកទេសរបស់ខ្លួនសម្រាប់កម្មវិធីជូនដំណឹងជាមុនពីក្សេត្រឧតុនិយម ( ហៅកាត់ថា SESAME) និងបានផ្ទេរប្រព័ន្ធនេះទៅឱ្យនាយកដ្ឋានកសិកម្ម។

កម្មវិធីនេះ អាចឱ្យនាយកដ្ឋានរដ្ឋាភិបាលសម្របសម្រួល និងផ្តល់ការណែនាំដែលកសិករងាយស្រួលទទួលបាន និងត្រូវបានកែសម្រួលទៅតាមបរិបទមូលដ្ឋានសម្រាប់ខេត្តនីមួយៗ ដំណាំ និងដំណាក់កាលលូតលាស់។

ពោតកំពុងលូតលាស់ក្នុងខេត្តកំពង់ធំ
(© Kelsea Clingeleffer/UNDP ប្រចាំនៅកម្ពុជា )



© ប៊ិត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា

# ការចែករំលែកឆ្លងដែន

“ការពិតគឺយើងមិនអាចសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង ១៧ ចំណុចបានទេ ប្រសិនបើយើងមិនទាញប្រយោជន៍ពីកិច្ចសហប្រតិបត្តិការចែករំលែកដំណោះស្រាយជាក់ស្តែង និងផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមកការបំផុស និងការជំរុញទៅតាមទិសដៅត្រឹមត្រូវ។”

**Achim Steiner ប្រធាន UNDP**

**ទីតាំង ៖** តំបន់អាស៊ីអាគ្នេយ៍

**គោលដៅ ៖** អ្នកជំនាញគ្រប់គ្រងគ្រោះមហន្តរាយ ដៃគូគម្រោង

**លទ្ធផលសំខាន់ៗ ៖**



១ សន្និសីទថ្នាក់តំបន់ ស្តីពីប្រព័ន្ធជូនដំណឹងជាមុនបានកៀរគរតំណាងមកពី ៥ ប្រទេស។

គ្រោះមហន្តរាយក្នុង
ប្រទេសមួយ អាចបង្កផលប៉ះពាល់
ដល់ប្រទេសជិតខាង។ ដូច្នេះ ចាំបាច់ត្រូវ
ពិចារណាពីវិធីសាស្រ្តឆ្លងដែនសម្រាប់
ការចែករំលែកទិន្នន័យ ព័ត៌មាន
និងការអនុវត្តល្អបំផុត។



ទឹកជំនន់ក្នុងតំបន់ទំនាបទន្លេមេគង្គ ប្រទេសថៃ និងឡាវ ខែ ធ្នូ ឆ្នាំ ២០១៥ (© NASA)



“យើងត្រូវធ្វើយ៉ាងណាឱ្យមានការចែករំលែកការអនុវត្តល្អពាក់ព័ន្ធនឹងប្រព័ន្ធជូនដំណឹងជាមុន ក្នុងអនុតំបន់ទន្លេមេគង្គក្រោមដើម្បីពង្រឹងសមត្ថភាពរបស់អង្គការគ្រប់គ្រងគ្រោះមហន្តរាយ និងបង្កើនភាពធន់របស់ប្រជាជនងាយរងគ្រោះ។”

**Federico Barreras ប្រធានកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយ អង្គការ People in Need**



ភូមិកំពង់ភ្លុក (© ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)

# សន្និសីទស្តីពីប្រព័ន្ធជូនដំណឹងជាមុនក្នុងតំបន់ទន្លេមេគង្គក្រោម

នៅខែ ធ្នូ ឆ្នាំ ២០១៩ សន្និសីទស្តីពីប្រព័ន្ធជូនដំណឹងជាមុនក្នុងតំបន់មេគង្គក្រោម បានកៀរគរតំណាងជាង ៨០ នាក់មកពីប្រទេសកម្ពុជា វៀតណាម ឡាវ ថៃ និងមីយ៉ាន់ម៉ា។

ផ្អែកតាមលទ្ធផលនៃការសិក្សាឆ្លងដែនក្នុងតំបន់ស្តីពីប្រព័ន្ធជូនដំណឹងជាមុនដែលធ្វើឡើងដោយដៃគូគម្រោង (អង្គការ People in Need) សន្និសីទនេះបានអញ្ជើញឱ្យប្រទេសនីមួយៗបង្ហាញពីប្រព័ន្ធជូនដំណឹងជាមុនរបស់ខ្លួន។ កិច្ចពិភាក្សា និងការបង្ហាញ លើកឡើងពីបច្ចេកវិទ្យាជូនដំណឹងជាមុន ដូចជា ការព្រីន សែនស័រទឹកតាមបែប 3D ដែលចូលរួមដោយអ្នកធ្វើបទបង្ហាញផ្សេងទៀត ដូចជា មជ្ឈមណ្ឌលត្រៀមខ្លួនទប់ទល់គ្រោះមហន្តរាយអាស៊ី គណៈកម្មការទន្លេមេគង្គ និង RIMES។

សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត បានចូលរួមក្នុងកិច្ចពិភាក្សាស្តីពីការពន្លឿនប្រព័ន្ធជូនដំណឹងជាមុនឆ្លងដែនក្នុងតំបន់នេះ។ អ្នកចូលរួមត្រូវបានលើកទឹកចិត្តឱ្យបង្កើតបណ្តាញសម្រាប់បង្កើនការចែករំលែកទិន្នន័យ និងការអនុវត្តល្អបំផុត។



ការព្រីនសែនស័រទឹកតាមបែប 3D កំពុងផ្លាស់ប្តូរសមត្ថភាពបង្កើតប្រព័ន្ធកំណត់រកមុខសញ្ញាគ្រោះថ្នាក់ដែលនឹងកើតឡើង
(© អង្គការ People in Need)





សហគមន៍តំបន់ឆ្នេរ បឹងកាចាង ខេត្តកោះកុង ខែ វិច្ឆិកា ឆ្នាំ ២០១៨
( © ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា )




លោក Muhibuddin Usamah ប្រធានគម្រោង ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ឆ្ពោះទៅរកការបង្កើតក្របខណ្ឌ និងផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (© ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)

# ការពន្លឿនការតាក់តែងគោលនយោបាយ

ដើម្បីបង្កើនចំណេះដឹង និងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយនិរន្តរភាព គម្រោងបានគាំទ្រដល់ការរៀបចំយុទ្ធសាស្ត្រជាតិ និងឯកសារស្រាវជ្រាវជាច្រើន ដូចខាងក្រោម ៖



នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ប្រព័ន្ធជូនដំណឹងជាមុនពីមុខសញ្ញាគ្រោះថ្នាក់ចម្រុះ

យុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងទឹកក្រោមដី

ការសិក្សាថ្នាក់ជាតិស្តីពីគ្រោះរាំងស្ងួតនៅកម្ពុជា

សៀវភៅណែនាំស្តីពីការគ្រប់គ្រងគ្រោះរាំងស្ងួតសម្រាប់កម្ពុជា និងក្របខណ្ឌជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៩-២០២៣ និងផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៩-២០២៣ គ្រោះមហន្តរាយ ២០១៩-២០២៣ និងផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៩-២០២៣





ភូមិកំពង់ភ្លុក ខែកក្កដា ឆ្នាំ២០១៩ ( © ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា )



## នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ប្រព័ន្ធជូនដំណឹងជាមុនពីមុខសញ្ញាគ្រោះថ្នាក់ចម្រុះ

ខណៈដែលប្លង់ចាស់នៃប្រព័ន្ធជូនដំណឹងជាមុនរបស់កម្ពុជាផ្តោតតែលើទឹកជំនន់ វិធីសាស្រ្តមុខសញ្ញាគ្រោះថ្នាក់ចម្រុះ ឆ្លុះបញ្ចាំងកាន់តែត្រឹមត្រូវពីលក្ខណៈចម្រុះនៃគ្រោះមហន្តរាយនៅកម្ពុជា។

ក្រោមការបង្កើតឡើងដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ប្រព័ន្ធជូនដំណឹងជាមុនពីមុខសញ្ញាគ្រោះថ្នាក់ចម្រុះ ផ្តោតលើការដាក់បញ្ចូលគោលនយោបាយ និងការរៀបចំផ្នែកស្ថាប័ននៅថ្នាក់ជាតិ ថ្នាក់ស្រុក និងថ្នាក់សហគមន៍ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។



រូបភាពពីលើអាកាសនៃផ្ទះជនបទមួយក្នុងខេត្តសៀមរាប (© ទូន គិមហៀង/UNDP ប្រចាំនៅកម្ពុជា)

## យុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងទឹកក្រោមដី

ការប្រែប្រួលអាកាសធាតុ ការបម្លែងដីសម្រាប់កសិកម្ម និងឧស្សាហកម្ម និងការប្រើប្រាស់កាន់តែច្រើនឡើង កំពុងបង្កផលប៉ះពាល់លើធនធានទឹកដ៏មានតម្លៃនៅកម្ពុជា។

យុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងទឹកក្រោមដី ផ្តោតលើដំណោះស្រាយសម្រាប់ការប្រើប្រាស់ទឹកក្រោមដីនៅកម្ពុជាប្រកបដោយនិរន្តរភាព ដូចជា អនុសាសន៍ស្តីពីការពង្រឹងការរៀបចំផ្នែកស្ថាប័ន និងការពង្រឹងការអនុវត្តច្បាប់ ការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងទិន្នន័យការបង្កើនការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ ការកសាងការយល់ដឹង និងការកៀរគរធនធាន។

ការរៀបចំផែនការ ធ្វើឡើងដោយគួបផ្សំនឹងការបណ្តុះបណ្តាលបុគ្គលិកមកពីនាយកដ្ឋានទឹកស្អាត និងអនាម័យ។

## យុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងគ្រោះរាំងស្ងួត

ផ្អែកតាមការសិក្សាស្រាវជ្រាវពីគ្រោះរាំងស្ងួត គម្រោងបានបង្កើតយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងគ្រោះរាំងស្ងួត ដោយផ្តល់អនុសាសន៍ស្តីពីរបៀបអនុវត្តគំរូនានាក្នុងការផ្តល់ការជូនដំណឹងជាមុនពីគ្រោះរាំងស្ងួតសម្រាប់កម្ពុជា។

## សៀវភៅណែនាំស្តីពីការគ្រប់គ្រងគ្រោះរាំងស្ងួតសម្រាប់អ្នកជំនាញ

សៀវភៅណែនាំស្តីពីការគ្រប់គ្រងគ្រោះរាំងស្ងួតដែលត្រូវបានបង្កើតឡើង ក្រោមកិច្ចសហការជាមួយ DanChurchAid រៀបរាប់ពីប្រធានបទនានា ដូចជា ការស្វែងយល់ពីវិសមរូបអាកាសធាតុ ទស្សនាទានគ្រោះរាំងស្ងួត និយមន័យ ការអនុវត្ត និងការវិភាគ សន្ទស្សន៍កំណកអាកាសស្តង់ដារ (precipitation) ការគ្រប់គ្រងហានិភ័យ និងករណីសិក្សា។



ភូមិត្របែក ខេត្តកំពង់ធំ ( © ឡាយ ចាន់សុខ/UNDP ប្រចាំនៅកម្ពុជា )






ការហាត់សមគ្រោះមហន្តរាយក្នុងសាលារៀននៅខេត្តកោះកុង
ប្រទេសកម្ពុជា (© ប៊ិត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)

# ក្របខណ្ឌជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៩-២០៣០ និងផែនការសកម្មភាព ៥ ឆ្នាំ

ក្រោមគម្រោងនេះ UNDP បានគាំទ្រដល់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយក្នុងការរៀបចំក្របខណ្ឌជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងផែនការសកម្មភាព ៥ ឆ្នាំ ២០១៩-២០២៣។

ក្របខណ្ឌជាតិ លើកឡើងពីវិធីសាស្រ្ត ៥ ដើម្បីពង្រឹងភាពធន់របស់កម្ពុជាទៅនឹងហានិភ័យគ្រោះមហន្តរាយ និងអាកាសធាតុ ៖

១.ការបង្កើនការយល់ដឹង និងចំណេះដឹងស្តីពីហានិភ័យគ្រោះមហន្តរាយ និងអាកាសធាតុ
២.ការវាយតម្លៃហានិភ័យគ្រោះមហន្តរាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
៣.ការពង្រឹងអភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ
៤.ការវិនិយោគលើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និង
៥.ការបង្កើនការត្រៀមខ្លួនសម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងការស្តារឡើងវិញ។

លទ្ធផលពីការវិភាគគ្រប់ជ្រុងជ្រោយលើផែនការកន្លងមក និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ផែនការសកម្មភាពទាំងនេះបានលម្អិតពីចំណុចនានា និងរបៀបអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅថ្នាក់ជាតិ។

ទន្ទឹមនឹងការសំយោគជាមួយច្បាប់ និងគោលការណ៍ណែនាំថ្នាក់ជាតិ ឯកសារទាំងនេះពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងរបៀបវារៈភាពធន់សកល ដូចជា ក្របខណ្ឌ Sendai សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ កិច្ចព្រមព្រៀងទីក្រុងប៉ារីសសម្រាប់សកម្មភាពប្រែប្រួលអាកាសធាតុ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។





សិក្ខាសាលាពិគ្រោះយោបល់ឆ្ពោះទៅរកការបង្កើតផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៩-២០២៣ (©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)



## ការសិក្សាពីការគ្រប់គ្រងទឹកជំនន់ និងប្រព័ន្ធជូនដំណឹងជាមុននៅដងស្ទឹងព្រែកត្នោត

ដើម្បីដោះស្រាយចំណុចខ្វះខាតក្នុងការគ្រប់គ្រងទឹកជំនន់ក្នុងអាងស្ទឹងព្រែកត្នោត នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេរបស់កម្ពុជាបានរៀបចំរបាយការណ៍មួយដើម្បីផ្តល់រូបភាពបច្ចុប្បន្នភាពនៃទឹកជំនន់ស្ទឹងព្រែកត្នោត និងការគ្រប់គ្រងបញ្ហានេះ។

របាយការណ៍នេះ ដែលនឹងផ្តល់ព័ត៌មានស្តីពីការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយ គូសបញ្ជាក់ពីលទ្ធផលរកឃើញសំខាន់ៗជាច្រើន ដូចជាផលប៉ះពាល់នៃការប្រែប្រួលការប្រើប្រាស់ដី និងការអភិវឌ្ឍ និងឱកាសសម្រាប់ការពង្រីកវិសាលភាពនៃហេដ្ឋារចនាសម្ព័ន្ធពិនិត្យតាមដានការទាញប្រយោជន៍ពីហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក ការបង្កើនកិច្ចសហប្រតិបត្តិការរវាងអ្នកពាក់ព័ន្ធ និងការកែលម្អនីតិវិធីនៃការជូនដំណឹងជាមុននៅកម្រិតមូលដ្ឋាន។

© ប៊ុន ថារុម (Flickr Creative Commons)



ការហាត់សមត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយក្នុងសាលារៀន ខេត្តកោះកុង (© ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)





ការដំឡើងស្ថានីយធាតុអាកាសស្វ័យប្រវត្តិ ក្រោមគម្រោងនេះ ឆ្នាំ២០១៨
(© ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)

## យុទ្ធសាស្ត្រជាតិសម្រាប់ការជំរុញការចូលរួមរបស់វិស័យឯកជនក្នុងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធជូនដំណឹងជាមុន

ការសហការជាមួយវិស័យសាធារណៈ៖ វិស័យឯកជនអាចគាំទ្រដល់ការដំណើរការ និងការជួសជុលថែទាំស្ថានីយជលសាស្ត្រ និងស្ថានីយជលសាស្ត្រឧតុនិយម និងផ្តល់ផលិតផល និងសេវាព័ត៌មានអាកាសធាតុ ដែលត្រូវបានកែសម្រួលទៅតាមតម្រូវការ។

ដើម្បីជួយជំរុញការចូលរួមរបស់វិស័យឯកជនក្នុងវិស័យទាំងនេះ គម្រោងបានធ្វើការពិនិត្យឡើងវិញលម្អិតលើតួអង្គវិស័យឯកជនដែលផលិត និងអាចប្រើប្រាស់ប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធជូនដំណឹងជាមុន (ឧ. រ៉េ អាកាសចរណ៍ និងធានារ៉ាប់រង) ការខ្វះខាតផលិតផល និងសេវា តំបន់ដែលត្រូវពង្រីកបន្ថែម គំរូអន្តរជាតិដែលត្រូវយកមករៀនសូត្រ និងថាតើវិស័យឯកជនមានឆន្ទៈវិនិយោគ ឬចំណាយលើព័ត៌មានអាកាសធាតុឬទេ។

លទ្ធផលរកឃើញពីការសិក្សានេះ និងយុទ្ធសាស្ត្រជាតិដែលបានបង្កើតឡើង ត្រូវបានផ្សព្វផ្សាយជូនក្រសួងធនធានទឹក និងឧតុនិយម កាលពីខែ ឧសភា ឆ្នាំ ២០២០។ ក្នុងពេលអនុវត្តគម្រោង UNDP បានជួបជាមួយវិស័យឯកជនដែលអាចក្លាយជាដៃគូសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា។



© liko solangkoun/UNDP ប្រចាំនៅកម្ពុជា

# ការធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យគ្រោះមហន្តរាយជាតិរបស់កម្ពុជា ( CAMDI )

នៅឆ្នាំ ២០១៥ ប្រព័ន្ធព័ត៌មានស្តីពីការខាតបង់ និងការខូចខាតដោយសារគ្រោះមហន្តរាយ (CAMDI) របស់កម្ពុជា ត្រូវបានបង្កើតឡើង ដើម្បីប្រមូល រក្សាទុក និងវិភាគទិន្នន័យស្តីពីការខាតបង់ និងការខូចខាតដោយសារគ្រោះមហន្តរាយ និងបង្កើនការយល់ដឹងពីហានិភ័យ និងភាពងាយរងគ្រោះ។ មានការបង្កើតក្រុមបច្ចេកទេសមួយដែលមានសមាសភាគមកពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង UNDP ដើម្បីប្រមូលទិន្នន័យស្តីពីគ្រោះមហន្តរាយពីទីភ្នាក់ងារផ្សេងៗនៅថ្នាក់ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ។

កិច្ចខិតខំប្រឹងប្រែងប្រមូលទិន្នន័យចំណាយពេលជាច្រើនខែ និងបានកត់ត្រាពីព្រឹត្តិការណ៍គ្រោះមហន្តរាយចំនួន ៧.៨០០ នៅអំឡុងឆ្នាំ ១៩៩៦-២០១៣។ ទិន្នន័យទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ការវិភាគនៅកម្រិតផ្សេងៗដោយប្រើប្រាស់បច្ចេកទេសចម្រុះ ដូចជាការវិភាគពេលវេលា លំហ និងសមាសភាគ ដើម្បីកំណត់រកទិដ្ឋភាពផ្សេងៗ និងលក្ខណៈនៃផលប៉ះពាល់។ ទោះជាយ៉ាងណា មិនសូវមានការធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យនេះឲ្យបានជាប់លាប់ឡើយ។

ក្រោមគម្រោងនេះ UNDP បានធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីការខូចខាត និងការខាតបង់ក្នុងប្រព័ន្ធ CAMDI នៅឆ្នាំ ២០២០ ដោយផ្អែកលើប្រវត្តិគ្រោះមហន្តរាយកន្លងមក និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់ CAMDI ដើម្បីឲ្យស៊ីសង្វាក់គ្នានឹងចំណុចដៅដែលបានកំណត់ក្នុងក្របខណ្ឌ Sendai សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។



ការទទួលបានព័ត៌មានបច្ចុប្បន្នភាព និងទិន្នន័យបើកចំហស្តីពីគ្រោះមហន្តរាយ មានសារៈសំខាន់ណាស់ក្នុងការតាក់តែងគោលនយោបាយ ការស្រាវជ្រាវ និងការស្វែងយល់ពីព្រឹត្តិការណ៍នាពេលអនាគត។



រូបភាពដើមកោងកាង ថតពីលើអាកាស ខេត្តកំពត (© ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា)





ភូមិកំពង់ភ្លុក
( ©សយ រដ្ឋា/UNDP ប្រចាំនៅកម្ពុជា )

( ©ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា )




ពីមុន អ្នកនេសាទចំណាំមើលមេឃ និងខ្យល់ដើម្បីព្យាករណ៍ធាតុអាកាស ប៉ុន្តែបច្ចុប្បន្ន ពួកគាត់អាចទទួលបានព័ត៌មានព្យាករណ៍តាមទូរទស្សន៍ វិទ្យុ និងទំព័រ Facebook របស់ក្រសួងធនធានទឹក និងឧតុនិយម (© អ៊ឹម សំរួល/UNDP ប្រចាំនៅកម្ពុជា)

# លទ្ធផលគម្រោង ៖

១. អ្នកជំនាញឧតុនិយម និងអ្នកជំនាញជលសាស្ត្រ ២៩នាក់ត្រូវបានបណ្តុះបណ្តាលពីការបង្កើតគំរូ និងការព្យាករណ៍។

២. កសិករ និងមន្ត្រីមន្ទីរ ២.៣៨៩ នាក់ (មន្ទីរកសិកម្ម មន្ទីរធនធានទឹក គណៈកម្មាធិការខេត្តគ្រប់គ្រងគ្រោះមហន្តរាយ) ត្រូវបានបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មដែលធន់នឹងគ្រោះរាំងស្ងួត(ស្ត្រី ១.៤២៥ នាក់)។

៣. ប្រជាពលរដ្ឋកម្ពុជា ២៤.៦២៨ នាក់បានទិញសេវាជូនដំណឹងជាមុន (EWS១២៩៤) ក្នុងបណ្តាខេត្តដែលគាំទ្រដោយ UNDP។

៤. ស្ត្រីឆ្នើម ២៣ នាក់ ត្រូវបានបណ្តុះបណ្តាលពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងប្រព័ន្ធជូនដំណឹងជាមុន

៥. ការបង្កើតភាពជាដៃគូចំនួន ៩ ដើម្បីពង្រឹងប្រព័ន្ធព័ត៌មានអាកាសធាតុ និងប្រព័ន្ធជូនដំណឹងជាមុន។

៦. វេទិកាថ្នាក់ជាតិចំនួន ៣ ស្តីពីចក្ខុវិស័យអាកាសធាតុ (វេទិកាខ្យល់មូសុង) ត្រូវបានរៀបចំឡើង។

៧. មជ្ឈមណ្ឌលព័ត៌មានគ្រោះរាំងស្ងួតចំនួន ៨ ត្រូវបានបង្កើតឡើង។

៨. ស្ថានីយធាតុអាកាសស្វ័យប្រវត្តិចំនួន ២៤ និងស្ថានីយជលសាស្ត្រស្វ័យប្រវត្តិចំនួន ២៩ ត្រូវបានដំឡើង។

៩. ប្រជាពលរដ្ឋចំនួន ១២.០២៨ នាក់ត្រូវបានបណ្តុះបណ្តាលក្នុងវគ្គបណ្តុះបណ្តាលជាង ៣១៥។

១០. អ្នកជំនាញឧតុនិយម អ្នកជំនាញជលសាស្ត្រ និងអ្នកបច្ចេកទេសចំនួន ៥៤ នាក់ត្រូវបានបណ្តុះបណ្តាលពីការដំណើរការ និងការជួសជុលថែទាំស្ថានីយអាកាសធាតុ និងស្ថានីយជលសាស្ត្រស្វ័យប្រវត្តិ។

- ✓ ការបង្កើតកម្មវិធីសិក្សាក្នុងសាលាវាល ស្តីពីការប្រើប្រាស់ការព្យាករណ៍សម្រាប់ការគ្រប់គ្រងហានិភ័យ (FARM)
- ✓ ការបង្កើតប្រព័ន្ធព្យាករណ៍អាកាសធាតុតាមរដូវ (FOCUS)
- ✓ ការសិក្សាថ្នាក់ជាតិស្តីពីគ្រោះរាំងស្ងួត
- ✓ ការបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងទឹកក្រោមដី និងការបណ្តុះបណ្តាលបុគ្គលិកមកពីនាយកដ្ឋានទឹកស្អាត និងអនាម័យ
- ✓ បញ្ចប់ការសិក្សាពីការគ្រប់គ្រងហានិភ័យទឹកជំនន់ និងប្រព័ន្ធជូនដំណឹងជាមុនតាមដងស្ទឹងព្រែកត្នោត
- ✓ បង្កើតនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ប្រព័ន្ធជូនដំណឹងជាមុននៅកម្ពុជា
- ✓ បង្កើតតំបន់ និងផែនទីអាកាសធាតុនៅកម្ពុជា
- ✓ ការរៀបចំក្របខណ្ឌជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (២០១៩-២០៣០) និងផែនការសកម្មភាពជាតិ ៥ ឆ្នាំ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (២០១៩-២០២៣)
- ✓ ការបង្កើតយុទ្ធសាស្ត្រជាតិស្តីពីការជំរុញការចូលរួមរបស់វិស័យឯកជន។



(© ប៊ុត ម៉ានុត/UNDP ប្រចាំនៅកម្ពុជា )




UNDP គឺជាស្ថាប័នឈានមុខមួយរបស់អង្គការសហប្រជាជាតិដែលខិតខំបញ្ឈប់អយុត្តិធម៌នៃភាពក្រីក្រ វិសមភាព និងការប្រែប្រួលអាកាសធាតុ។ ក្រោមកិច្ចសហការជាមួយបណ្តាញអ្នកជំនាញ និងដៃគូយ៉ាងទូលំទូលាយរបស់យើងក្នុង ១៧០ ប្រទេស យើងបានជួយដល់ប្រជាជាតិនានាក្នុងការកសាងដំណោះស្រាយចម្រុះ និងយូរអង្វែងសម្រាប់មនុស្សជាតិ និងភពផែនដី។

សូមស្វែងយល់បន្ថែមតាមគេហទំព័រ undp.org ឬចូលទៅកាន់ @UNDP។